## 1.8 សេចក្តីណែនាំដែលបានអនុវត្តតាមរយៈសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត

### 1.8.1 សេចក្តីណែនាំ – ទូទៅ

ដរាបណាមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងគណនីដែលបានភ្ជាប់របស់ម្ចាស់គណនី និង អាស្រ័យលើការកាត់ចេញជាមុននោះ សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនឹងអនុញ្ញាតឲ្យលោកអ្នកអនុវត្តដូចខាងក្រោមនេះ៖

(a) ការផ្ទេរវាង My Accounts

(b) សំណើការផ្ទេររូបិយប័ណ្ណផ្សេងៗ

(c) សំណើផ្ទេរក្នុងប្រទេស

(d) សំណើផ្ទេរទៅបរទេស

(e) សំណើសុំរូបិយាណត្តិធនាគារ

(f) ទូទាត់វិក្កយបត្រ

(g) ការចំណាយទូទាត់បៀវត្ស

(h) ការចំណាយទូទាត់ជាកញ្ចប់ ឬតាម Diskpay

(i) សំណើសុំយករបាយការណ៍ទ្វេដង និង

(j) សំណើសុំសៀវភៅមូលប្បទានប័ត្រថ្មី

(យោងជារួមហៅថា "សេចក្តីណែនាំ")

ការកំហិត និង លក្ខខណ្ឌផ្សេងៗទៀត អាចត្រូវអនុវត្តផងដែរយោងតាមច្បាប់ ឬ យោងតាមគោលនយោបាយរបស់ធនាគារ ANZ Royal ក្នុងករណីនោះធនាគារ ANZ Royal នឹងជូនដំណឹងលោកអ្នកអំពីការកំហិត និង លក្ខខណ្ឌទាំងនេះ។

លោកអ្នកត្រូវយល់ព្រមថា ប្រសិទ្ធភាពនៃសេចក្តីណែនាំរបស់លោកអ្នក និង ការឆ្លើយតប ឬ សេចក្តីជូនដំណឹងរបស់ធនាគារ ANZ Royal ដែលបានផ្តល់ជូនតាមរយៈគេហទំព័រសេវាធនាគារ ANZ Royal នឹងមានប្រសិទ្ធភាពដូចគ្នាប្រសិនបើបានផ្តល់ជូនជាលាយលាក់អក្សរផងដែរ។

### 1.8.2 យន្តការដោះស្រាយ

អាស្រ័យលើកឋាខ័ណ្ឌ 1.8.3, 1.8.4 និង 1.9 ធនាគារ ANZ Royal ត្រូវដំណើរការដោះស្រាយជាទូទៅដូចខាងក្រោមនេះ៖

(a) ការផ្ទេរប្រាក់រវាងគណនីខ្ញុំ (My Account) និង សេចក្តីណែនាំអំពីការចំណាយទូទាត់វិក័យប័ត្រនៅថ្ងៃដដែលនោះ គឺត្រូវបានទទួលដោយធនាគារ ANZ Royal ឬ

(b) សំណើផ្ទេរប្រាក់ជារូបិយប័ណ្ណផ្សេងៗ សំណើផ្ទេរប្រាក់ក្នុងប្រទេស សំណើផ្ទេរប្រាក់ទៅបរទេស សំណើរូបិយាណត្តិធនាគារ ការចំណាយទូទាត់ប្រាក់បៀវត្ស ការចំណាយទូទាត់ជាកញ្ចប់ (Diskpay) សំណើសៀវភៅមូលប្បទានប័ត្រថ្មី និង សំណើរបាយការណ៍ចម្លងអំពីប្រតិបត្តិការគណនី នៅក្នុងពេលវេលាដោះស្រាយអាចនឹងមានការផ្លាស់ប្តូរជាមុនដោយគ្មានការជូនដំណឹង និង យោងតាមលក្ខខណ្ឌដែលបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងដោយធនាគារ ANZ Royal ជាបន្តបន្ទាប់។

### 1.8.3 រូបិយប័ណ្ណ

ការដាក់ ឬដកប្រាក់ណាមួយចេញពីគណនីលោកអ្នក តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតជារូបិយវត្ថុមួយផ្សេងពីរូបិយវត្ថុដែលគណនីលោកអ្នកបានកំណត់នោះ គឺអាស្រ័យលើះ

(a) បញ្ញត្តិ និង កំហិតសម្រាប់ត្រួតពិនិត្យអត្រាប្តូរប្រាក់ដែលអាចអនុវត្តបានក្រោមច្បាប់ជាតិ ក្នុងករណីដែលធនាគារ ANZ Royal នឹងជូនដំណឹងលោកអ្នកអំពីការកំហិត/លក្ខខណ្ឌទាំងនេះ។ លើសពីនេះ លោកអ្នកអាចទាក់ទងតាមសាខាធនាគារ ANZ Royal របស់លោកអ្នកសម្រាប់ព័ត៌មានបន្ថែម និង

(b) អត្រាប្តូរប្រាក់ដែលអាចអនុវត្តបានចំពោះរូបិយវត្ថុនៃប្រតិបត្តិការដែលបញ្ចូលនៅថ្ងៃប្រតិបត្តិការនោះ។ ធនាគារ ANZ Royal នឹងកំណត់លើអត្រាប្តូរប្រាក់នានាដើម្បីផ្ទេរចំនួនទឹកប្រាក់ជារូបិយប័ណ្ណបរទេសទៅជាចំនួនទឹកប្រាក់ដែលមានតម្លៃស្មើនៅក្នុងរូបិយប័ណ្ណបរទេសផ្សេងទៀត ឬ រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលអាស្រ័យទៅលើប្រតិបត្តិការដែលមានបញ្ហានេះ ដោយយោងទៅតាមនីតិវិធីដែលមានបទដ្ឋានត្រឹមត្រូវរបស់ធនាគារ ANZ Royal សម្រាប់ការផ្ទេរ ឬ បម្លែងរូបិយប័ណ្ណ។

### 1.8.4 លក្ខខណ្ឌបន្ថែម

ធនាគារ ANZ Royal អាចត្រូវការព័ត៌មាន ឬការបញ្ជាក់លម្អិតបន្ថែមទៀត មុននឹងដំណើរការដោះស្រាយសំណើសុំតាមសេចក្តីណែនាំរបស់លោកអ្នក។

### 1.8.5 ឯកសារយោងសម្រាប់ប្រតិបត្តិការ

ធនាគារ ANZ Royal នឹងចេញឯកសារយោងសម្រាប់ប្រតិបត្តិការជូនចំពោះលោកអ្នក ឬអ្នកប្រើប្រាស់ (ដែលជាករណីអាចនឹងកើតមាន) ដើម្បីបញ្ជាក់អំពីការទទួលបានសេចក្តីណែនាំលើការផ្ទេរប្រាក់រវាងគណនីខ្ញុំ (My Accounts) សំណើផ្ទេរប្រាក់ជារូបិយប័ណ្ណផ្សេងៗ សំណើផ្ទេរប្រាក់ក្នុងប្រទេស សំណើផ្ទេរប្រាក់ទៅបរទេស សំណើរូបិយាណត្តិធនាគារ ការចំណាយទូទាត់វិក្កយប័ត្រ ការចំណាយទូទាត់លើប្រាក់បៀវត្ស ការចំណាយទូទាត់កញ្ចប់ (Diskpay) សំណើសុំសៀវភៅមូល្យទានប័ត្រថ្មី សំណើរបាយការណ៍ចម្លងអំពីប្រតិបត្តិការគណនីនៅលើគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

## 1.9 សេចក្តីណែនាំអំពីដំណើរការដោះស្រាយ - ទូទៅ

### 1.9.1 ស្ថានភាពទូទៅ

លោកអ្នក ត្រូវតែផ្តល់នូវព័ត៌មានដែលស្នើដោយធនាគារ ANZ Royal ដើម្បីដំណើរការដោះស្រាយតាមសេចក្តីណែនាំរបស់លោកអ្នក តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ សេចក្តីណែនាំរបស់លោកអ្នក នឹងមិនទទួលយកមកដំណើរការដោះស្រាយទេ ប្រសិនបើ:

(a) រាល់ព័ត៌មានដែលចាំបាច់ មិនបានផ្តល់ឲ្យ

(b) ការអនុញ្ញាតមិនបានធ្វើឡើងនៅក្នុងរយៈពេលម្ភៃប្រាំបីថ្ងៃ (28) នៅពេលដែលសេចក្តីណែនាំត្រូវបានផ្តើមឡើងដំបូងតាមគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

(c) ការអនុញ្ញាតជារួម មិនបានធ្វើឡើងចំពោះម្ចាស់គណនីបានជ្រើសរើសដើម្បីដំណើរការដោះស្រាយប្រតិបត្តិការដែលត្រូវអាស្រ័យលើលក្ខខណ្ឌការអនុញ្ញាតជារួមជាមុនសិន

(d) មានទឹកប្រាក់មិនគ្រប់គ្រាន់នៅក្នុងគណនីផ្គត់ផ្គង់សាច់ប្រាក់ដែលបានកំណត់ ឬ

(e) ធនាគារ ANZ Royal ត្រូវបាន (ទោះជាក្នុងហេតុផលណាក៏ដោយ) គេកំហិត ឬ ហាមប្រាមដោយច្បាប់ពីការអនុញ្ញាតការចំណាយទូទាត់ដែលអាចនឹងកើតមានឡើង។

ធនាគារ ANZ Royal មិនមានកាតព្វកិច្ចទទួលយកសេចក្តីណែនាំទាំងឡាយណា និងមានការប្រុងប្រយ័ត្នយ៉ាងពេញលេញចំពោះការទទួលយក ឬ ប្រព្រឹត្តតាម (ឬ បដិសេធការទទួល ឬ ប្រព្រឹត្តតាម) សេចក្តីណែនាំទាំងណាមួយដែលបានដាក់ជូនតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ លើសពីនេះ ធនាគារ ANZ Royal អាចនឹងពន្យាប្រតិបត្តិការ តាមសេចក្តីណែនាំ ឬ អាចសាកសួរម្ចាស់គណនី ឬ អ្នកប្រើប្រាស់ សម្រាប់ព័ត៌មានបន្ថែម មុននឹងបន្តអនុវត្តតាមសេចក្តីណែនាំនោះ។ លោកអ្នក អាចពិនិត្យមើលលើស្ថានភាពនៃសេចក្តីណែនាំរបស់ខ្លួនតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតទំនាក់ទំនងតាមរយៈមណ្ឌលជំនួយផ្នែកសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

ធនាគារ ANZ Royal មិនត្រូវបានគេតម្រូវឲ្យ និងមិនត្រួតពិនិត្យលើ ព័ត៌មានលម្អិតដែលផ្តល់ដោយម្ចាស់គណនី ឬ អ្នកប្រើប្រាស់ នៅលើទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ថាពិតជាត្រឹមត្រូវ ឬ មិនត្រឹមត្រូវនោះទេ។ កំហុសឆ្គងណាមួយក្នុងការវាយបញ្ចូលព័ត៌មានទាំងនេះ អាចនឹងបណ្តាលឲ្យទឹកប្រាក់ផ្ទេរចូលទៅក្នុងគណនីមិនត្រឹមត្រូវ ឬ ចំនួនទឹកប្រាក់មិនត្រឹមត្រូវ និងរូបិយវត្ថុ ឬ សេចក្តីណែនាំមិនកំពុងត្រូវបានគេធ្វើឡើងទេ។ ធនាគារ ANZ Royal មិនទទួលខុសត្រូវចំពោះភាពមិនត្រឹមត្រូវណាមួយនៅក្នុងសេចក្តីណែនាំដែលបានផ្តល់ដោយម្ចាស់គណនី ឬ អ្នកប្រើប្រាស់ ឬ ធនាគារមិនទទួលខុសត្រូវចំពោះបញ្ហាការខូចខាតដែលនឹងកើតមកពីភាពមិនត្រឹមត្រូវនៅក្នុងសេចក្តីណែនាំនោះទេ។

នៅពេលធនាគារ ANZ Royal មានសេចក្តីណែនាំសម្រាប់ការផ្ទេរប្រាក់ច្រើនជាងមួយលើកចេញពីគណនីដែលបានភ្ជាប់របស់ម្ចាស់គណនីដែលបានធ្វើតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal នោះ ស្ថិតក្នុងឆន្ទានុសិទ្ធិពេញលេញរបស់ខ្លួន ធនាគារ ANZ Royal នឹងកំណត់មើលលំដាប់ជាអាទិភាពនេះ ក្នុងករណីដែលការផ្ទេរប្រាក់នេះត្រូវបានគេបង្កើតឡើង។

លើសពីនេះ បើមិនមានចែងសម្គាល់នៅក្នុងកឋាខ័ណ្ឌ 1.9.2 ទេនោះ សេចក្តីណែនាំណាមួយដែលបានផ្តល់ដោយម្ចាស់គណនី ឬ អ្នកប្រើប្រាស់តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត មិនអាចត្រូវបានបោះបង់ ឬ លុបចោល ឬ ប្តូរ ឬ កែតម្រូវណាមួយឡើយ ដោយសារថាធនាគារ ANZ Royal បានចេញឲ្យនូវលេខយោងមួយ។

ម្ចាស់គណនី អនុញ្ញាតឲ្យធនាគារ ANZ Royal អនុវត្តតាម និង ដំណើរការដោះស្រាយនូវសេចក្តីណែនាំណាមួយដែលម្ចាស់គណនី ឬ អ្នកប្រើប្រាស់ (តំណាងម្ចាស់គណនី)អោយផ្តល់ ឬ បញ្ជូនព័ត៌មានតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal

តាមប្រព័ន្ធអ៊ីនធឺណែត ដោយប្រើប្រាស់អត្តសញ្ញាណអ្នកប្រើប្រាស់ និង ពាក្យសម្ងាត់របស់ខ្លួន ដោយធនាគារ ANZ Royal មិនចាំបាច់ស្វែងរកការបញ្ជាក់បន្ថែម ឬ ផ្តល់ការជូនដំណឹងដល់ ពីម្ចាស់គណនីនោះឡើយ។

ស្ថិតក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារ ANZ Royal អាចនឹងបញ្ជាក់សេចក្តីណែនាំរបស់លោកអ្នកជាបន្តបន្ទាប់ តាមទូរស័ព្ទ មុននឹងដំណើរការដោះស្រាយសេចក្តីណែនាំណាមួយ។

លើកលែងតែករណីដូចមានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់គេហទំព័រ ម្ចាស់គណនីមានទំនួលខុសត្រូវចំពោះធនាគារ ANZ Royal និងយល់ព្រមធានាសងឲ្យធនាគារ ANZ Royal លើរាល់ទង្វើដែលកើតមានដោយសារមូលហេតុ:

(a) ធនាគារ ANZ Royal ទទួលយក ឬ អនុវត្តតាមលើសេចក្តីណែនាំណាមួយ ដោយយោងទៅតាមលក្ខខណ្ឌប្រើប្រាស់ទាំងនេះ

(b) អសុពលភាព ឬ ការដោះសារអំពីអសុពលភាពនៃសេចក្តីណែនាំណាមួយ ឬ ប្រតិបត្តិការដែលមានពាក់ព័ន្ធនៅក្នុងនោះ មានជាអាទ៍: សេចក្តីណែនាំ ឬ ប្រតិបត្តិការទាំងឡាយណាដែលវាយបញ្ចូលដោយតំណាងម្ចាស់គណនីដែលមិនទាន់ទទួលបានការអនុញ្ញាតពីធនាគារ ANZ Royal

(c) ធនាគារ ANZ Royal មិនអនុវត្តតាម ឬ ទទួលយកនូវសេចក្តីណែនាំមួយ ដោយយោងទៅតាមលក្ខខណ្ឌទាំងនេះ ឬ

(d) ការពន្យារបស់ធនាគារ ANZ Royal នៅក្នុងការអនុវត្តន៍តាម ឬទទួលយកសេចក្តីណែនាំមួយ ដោយយោងទៅលើលក្ខខណ្ឌប្រើប្រាស់ទាំងនេះ ។

## 1.9.2 សេចក្តីណែនាំអំពីការលុប ឬ រំលងចោល

ត្រង់ចំណុចដែលសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត អនុញ្ញាតឲ្យលោកអ្នកដាក់សំណើ ឬ ប្រតិបត្តិការផ្ទេរប្រាក់ជាបន្តបន្ទាប់តាមកាលបរិច្ឆេទកំណត់នោះ លោកអ្នកអាចនឹង:

(a) លុបចោលនូវការផ្ទេរមួយដែលបានកំណត់កាលបរិច្ឆេទនៅពេលខាងមុខ ឬ

(b) លុប ឬ រំលងចោលនូវការផ្ទេរបន្ទាប់នៅពេលក្រោយមកទៀត

បើសិនជា:

(i) ធនាគារ ANZ Royal មិនទាន់បានចាប់ផ្តើម ឬដំណើរការសេចក្តីណែនាំប្រភេទបែបនោះ និង

(ii) ធនាគារ ANZ Royal ទទួលបានសេចក្តីណែនាំ ដើម្បីលុប ឬ រំលងចោលនូវការផ្ទេរ/ចំណាយទូទាត់ (ដែលករណីអាចនឹងកើតមានឡើង) ពីម្ចាស់គណនី ឬ តំណាងម្ចាស់គណនីដែលបានចាប់ផ្តើមការផ្ទេរប្រាក់ជាបន្តបន្ទាប់ និង តាមកាលបរិច្ឆេទសម្រាប់ពេលខាងមុខតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនៅមុនម៉ោង 12.00យប់ (ពាក់កណ្តាលអាធ្រាត ម៉ោងក្នុងស្រុក) នៅថ្ងៃធ្វើការរបស់ធនាគារ ANZ Royal មុនកាលបរិច្ឆេទនៃការទូទាត់ចំណាយ។

## 1.10 ព័ត៌មានអំពីគណនី

សមតុល្យ នៃគណនីដែលបានភ្ជាប់ណាមួយដែលលោកអ្នកទទួលបានតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត នឹងជាសមតុល្យបច្ចុប្បន្នដែលនៅពេលអ្នកសាកសួរ ហើយអាចនឹងរួមមានសាច់ប្រាក់មិនទាន់ផាត់ទាត់ (មិនទាន់ជម្រះបញ្ជី) (ឧទាហរណ៍: មូលប្បទានប័ត្រដែលមិនទាន់បានផាត់ទាត់)។

នៅពេលលោកអ្នកទទួលបានសមតុល្យគណនី ចំនួនទឹកប្រាក់អតិបរមាដែលលោកអ្នកអាចដកបានចេញពីគណនីដែលបានភ្ជាប់ ក៏នឹងបង្ហាញឲ្យឃើញផងដែរ ដោយអាស្រ័យលើកម្រិតចំនួនទឹកប្រាក់ទាំងឡាយណាដែលអាចនឹងអនុវត្តបាននៅលើគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ជាទូទៅចំនួនទឹកប្រាក់អតិបរមានេះ នឹងឆ្លុះបញ្ចាំងឲ្យឃើញនូវ:

(a) កម្រិតឥណទានណាមួយដែលមានលើគណនី

(b) ទឹកប្រាក់ទាំងឡាយដែលបានផ្ទេរ តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត នៅថ្ងៃធ្វើការរបស់ធនាគារ ANZ Royal និង

(c) ការដាក់ ឬ ដកប្រាក់ទាំងឡាយណាដែលបានធ្វើនៅតាមបណ្តាសាខាធនាគារ ANZ Royal នៅចំថ្ងៃធ្វើការ របស់ធនាគារ ANZ។

លោកអ្នក ក៏អាចស្វែងរក និង ពិនិត្យមើលបានផងដែរលើរាល់ប្រតិបត្តិការដែលបានធ្វើលើគណនីសម្រាប់ដាក់ប្រាក់របស់លោកអ្នកដែលបានភ្ជាប់ (រហូតដល់365ថ្ងៃចុងក្រោយ) និង ប្រតិបត្តិការចំនួន20 ចុងក្រោយ ដែលបានធ្វើនៅគណនីកម្ចីរបស់លោកអ្នកដែលបានភ្ជាប់ នៅលើគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ លើសពីនេះ លោកអ្នកអាចទាញយកខ្លឹមសារលម្អិតអំពីប្រតិបត្តិការទាំងនេះចេញពីលទ្ធផលនានាដែលបានបង្ហាញឲ្យឃើញទាំងនៅលើទម្រង់ឯកសារនៃកម្មវិធី Microsoft Excel និងកម្មវិធីសម្រាប់ទិន្នន័យ (spreadsheet programs) ផ្សេងៗទៀតជាទម្រង់ឯកសារ CSV។

## 1.11 ការបន្ថែមសេចក្តីអធិប្បាយទៅលើគណនីមួយ

លោកអ្នក អាចបន្ថែមសេចក្តីអធិប្បាយមួយអំពីជម្រើសរបស់ខ្លួនទៅនឹងគណនីដែលម្ចាស់គណនីបានកំណត់ប្រើប្រាស់រួចហើយដើម្បីភ្ជាប់ទៅនឹងគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ការបន្ថែមសេចក្តីអធិប្បាយលើគណនីមួយ នឹងផ្លាស់ប្តូរនូវឈ្មោះនៃសេចក្តីអធិប្បាយរបស់គណនីដោយសារវាលេចចេញឲ្យឃើញតែលើគេហទំព័រសេវាកម្មធនាគារ ANZ Royal តែប៉ុណ្ណោះសម្រាប់រាល់គណនីដែលបានភ្ជាប់ទៅនឹងអត្តសញ្ញាណអ្នកប្រើប្រាស់របស់លោកអ្នក។ វានឹងមិនផ្លាស់ប្តូរកំណត់ហេតុជាផ្លូវការរបស់ធនាគារ ANZ Royal ឬ ឈ្មោះ គណនីរបស់អ្នកប្រើប្រាស់ផ្សេងៗទៀតដែលកំពុងប្រើប្រាស់អត្តលេខ ឬ អត្តសញ្ញាណអ្នកប្រើប្រាស់ផ្សេងទៀត ដើម្បីមានលទ្ធភាពប្រើប្រាស់ចំពោះគណនីដែលបានភ្ជាប់ទៅនឹងគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ការបន្ថែមសេចក្តីអធិប្បាយលើគណនីមួយដែលមានភ្ជាប់ជាមួយនឹងគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត គឺគ្រាន់តែសម្រាប់ភាពងាយស្រួលរបស់លោកអ្នកតែប៉ុណ្ណោះ។ ធនាគារ ANZ Royal នឹងមិនទទួលខុសត្រូវចំពោះការទទួលដាក់ប្រាក់ចូលទៅក្នុងគណនីណាមួយលើមូលដ្ឋានដែលគេត្រូវទទួលបានការបំរុងទុក ឬ ប្រើប្រាស់សម្រាប់គោលបំណងពិសេសណាមួយជាធម្មតា ដោយសារលោកអ្នកបានជ្រើសរើសបញ្ចូលបន្ថែមនូវសេចក្តីអធិប្បាយមួយទៅនឹងគណនីនោះសម្រាប់គោលបំណងនៃការប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតតែប៉ុណ្ណោះ។ រាល់ការតម្កល់ប្រាក់ដែលត្រូវបានធ្វើឡើងចំពោះគណនីលោកអ្នក នឹងទទួលបានការដោះស្រាយក្នុងរយៈពេលធម្មតានៃថ្ងៃធ្វើការ។

## 1.12 ការបន្តប្រើប្រាស់សេវាតារាងបៀវត្សនិយោជិត

ធនាគារ ANZ Royal អនុញ្ញាតដល់ប្រភេទអ្នកប្រើប្រាស់ ដូចមានរាយខាងក្រោមនេះ ដើម្បីប្រើប្រាស់មុខងារការបន្តប្រើប្រាស់តារាងបៀវត្ស (Maintain Employee Payroll) សម្រាប់អ្វីដែលការចំណាយទូទាត់បៀវត្សដែលគេអាចចាប់ផ្តើមតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត:

a. ហត្ថលេខី(តំណាង)ដែលមានការអនុញ្ញាត - (កម្រិតទី1)

b. អ្នកគ្រប់គ្រងក្រុមហ៊ុន (កម្រិតទី1 & 2)

c. អ្នកធ្វើប្រតិបត្តិការក្រុមហ៊ុន

បញ្ជីឈ្មោះនិយោជិត គឺមានលក្ខណៈអាចមើលបានដោយអ្នកប្រើប្រាស់ទាំងអស់ ឬ តំណាងម្ចាស់គណនីដែលអាចចាប់ផ្តើមធ្វើការចំណាយទូទាត់បៀវត្សតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតបាន។

## 1.13 ការបោះបង់ ឬ ព្យួរចោលពាក្យសម្ងាត់ អត្តលេខអ្នកប្រើប្រាស់ ឬ លទ្ធភាពប្រើប្រាស់ជាលក្ខណៈអេឡិចត្រូនិក

ធនាគារ ANZ Royal អាចនឹងបោះបង់ ឬ ព្យួរចោលពាក្យសម្ងាត់ អត្តលេខ ឬ លទ្ធភាពប្រើប្រាស់ជាលក្ខណៈអេឡិចត្រូនិកណាមួយបាន:

(a) ដោយគ្មានការជូនដំណឹងជាមុន (ប្រសិនបើមិនមានបម្រាមដោយច្បាប់) ក្នុងករណីដូចខាងក្រោមនេះ:

- ធនាគារ ANZ Royal សង្ស័យចំពោះម្ចាស់គណនី ឬ តំណាងម្ចាស់គណនីដែលមានការអនុញ្ញាត ចំពោះបញ្ហាការក្លែងបន្លំ ឬ ចូលរួមនៅក្នុងការប្រព្រឹត្តមិនត្រឹមត្រូវ
- ធនាគារ ANZ Royal ជឿជាក់ថា ការប្រើប្រាស់អត្តលេខ ឬ ការប្រើប្រាស់ជាលក្ខណៈអេឡិចត្រូនិករបស់ម្ចាស់គណនី ឬ តំណាងម្ចាស់គណនីដែលមានការអនុញ្ញាត អាចនឹងបណ្តាលអោយខូចខាតដល់ម្ចាស់គណនី ឬ ធនាគារ ANZ Royal
- គណនីនេះ គឺជាគណនីអសកម្ម
- រាល់គណនីទាំងអស់ដែលអត្តលេខអ្នកប្រើប្រាស់មានទំទាក់ទំនង ត្រូវបានគេបិទចោល
- គណនីនេះ បានដកប្រាក់លើស ឬ ម្ចាស់គណនីនេះ បានដកប្រាក់លើសកម្រិតចំនួនទឹកប្រាក់ឥណទានតាមការព្រមព្រៀងនៅក្នុងគណនីជាមួយនឹងធនាគារ ANZ Royal
- ប្រព័ន្ធបច្ចេកទេស ឬ ឧបករណ៍មធ្យោបាយបំពេញមុខងារនៃធនាគារ ANZ Royalគឺខូចឬមិនអាចប្រើប្រាស់បាន
- ធនាគារ ANZ Royal ជឿជាក់ថា បញ្ហា សុវត្ថិភាពនៃការប្រើប្រាស់តាមអេឡិចត្រូនិករបស់ម្ចាស់គណនី ឬ តំណាងម្ចាស់គណនីដែលមានការអនុញ្ញាត ឬ ប្រព័ន្ធនិងឧបករណ៍មធ្យោបាយបំពេញមុខងារនៃធនាគារ ត្រូវបានគេធ្វើឲ្យមានបញ្ហា

- ពាក្យសម្ងាត់ ត្រូវបានវាយបញ្ចូលមិនត្រឹមត្រូវចំនួនបី (3) ដង

- ច្បាប់តម្រូវអោយធនាគារ ANZ Royal ធ្វើដូច្នេះ។

## 1.14 សុវត្ថិភាពនៃពាក្យសម្ងាត់ និង អត្តលេខសម្គាល់អ្នកប្រើប្រាស់

លោកអ្នក ត្រូវតែរក្សាទុកពាក្យសម្ងាត់ និង អត្តលេខ ឬ អត្តសញ្ញាណសម្រាប់អ្នកប្រើប្រាស់របស់លោកអ្នកឲ្យមានសុវត្ថិភាព។ ការខកខានអនុវត្តដូច្នោះ អាចនឹងបង្កើននូវភាពទទួលខុសត្រូវរបស់ម្ចាស់គណនីសម្រាប់បញ្ហាខូចខាតណាមួយ។

លោកអ្នក:

- មិនត្រូវប្រាប់ទៅអ្នកណាម្នាក់អំពីពាក្យសម្ងាត់របស់លោកអ្នកជាដាច់ខាត

- មិនត្រូវអនុញ្ញាតអ្នកផ្សេងមើលលោកអ្នកវាយបញ្ចូលពាក្យសម្ងាត់ជាដាច់ខាត

- ត្រូវធ្វើយ៉ាងណាចងចាំពាក្យសម្ងាត់លោកអ្នកឲ្យបានល្អ និង មិនត្រូវកត់ត្រាវានៅកន្លែងណាមួយជាដាច់ខាត

- មិនត្រូវជ្រើសរើសពាក្យសម្ងាត់ណាមួយដែលងាយនឹងគេស្គាល់នោះទេ ឧទាហរណ៍: ថ្ងៃខែឆ្នាំកំណើត លេខចុះបញ្ជីរថយន្ត លេខទូរស័ព្ទ ឬ ឈ្មោះរបស់លោកអ្នក និង

- មិនត្រូវប្រើប្រាស់ពាក្យសម្ងាត់ដូចគ្នាសម្រាប់គោលបំណងផ្សេងទៀតណាមួយ ក្រៅពីគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

លោកអ្នក ត្រូវតែអនុលោមតាមគោលការណ៍ណែនាំអំពីបញ្ហាសុវត្ថិភាពដែលចេញដោយធនាគារ ANZ Royal (ដូចដែលបានធ្វើវិសោធនកម្ម ឬ បច្ចុប្បន្នភាពជាបន្តបន្ទាប់) នៅពេលលោកអ្នកប្រើប្រាស់គេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

ធនាគារ ANZ Royal លើកទឹកចិត្តឲ្យលោកអ្នកប្តូរពាក្យសម្ងាត់របស់លោកអ្នកអោយបានទៀងទាត់។ ដើម្បីប្តូរពាក្យ សម្ងាត់លោកអ្នក អាចធ្វើតាមទាំងសេចក្តីណែនាំដែលមានចែងនៅក្នុងផ្នែកនៃមុខងារកម្រងព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំ "My Profile" គឺផ្ទាំង "Profile" ដែលមាននៅលើគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតឬទាក់ទងមណ្ឌលជំនួយផ្នែកសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតលើបញ្ហាព័ត៌មានលម្អិតដែលដាក់ចេញនៅឯចុងបញ្ចប់នៃឯកសារនេះ។

ប្រសិនបើ ពាក្យសម្ងាត់ និង/ឬ អត្តលេខសម្រាប់អ្នកប្រើប្រាស់របស់លោកអ្នក មានការបាត់បង់ ឬ ត្រូវបានគេលួចយក ឬ ប្រតិបត្តិការដែលគ្មានការអនុញ្ញាតបានកើតមានឡើងលើគណនីលោកអ្នកដែលបានភ្ជាប់តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត លោកអ្នកត្រូវតែជូនដំណឹងមកធនាគារ ANZ Royal ជាបន្ទាន់។

## 1.15 ប្រតិបត្តិការដែលគ្មានការអនុញ្ញាត

កឋាខ័ណ្ឌ 1.15 នេះ មានចែងអំពីទំនួលខុសត្រូវរបស់ភាគីសម្រាប់បញ្ហាប្រតិបត្តិការដែលគ្មានការអនុញ្ញាតដែលត្រូវបានគេអនុវត្ត តាមរយៈគេហទំព័រសេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណែត។

### 1.15.1 ដំណាក់កាលដែលធនាគារ ANZ Royal មានទំនួលខុសត្រូវ

ធនាគារ ANZ Royal នឹងមានទំនួលខុសត្រូវសម្រាប់រាល់បញ្ហាការខូចខាតជាក់ស្តែង ដោយសារម្ចាស់គណនីដែល:

(a) ទទួលរងនូវបញ្ហាក្លែងបន្លំ ឬ មានការធ្វេសប្រហែសដោយបុគ្គលិក ឬ ភ្នាក់ងាររបស់ធនាគារ ANZ Royal

(b) មានពាក់ព័ន្ធនឹងកំហុសដែលកើតមានឡើងនៅលើប្រព័ន្ធកម្មវិធីគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ប្រសិនបើកំហុសទាំងនោះមិនមានលក្ខណៈពិតប្រាកដ ឬ ណែនាំតាមរយៈសារ ឬ ការជូនដំណឹងប្រាប់លើអេក្រង់។

(c) លេចចេញពីប្រតិបត្តិការដែលតម្រូវអោយប្រើពាក្យសម្ងាត់ណាមួយដែលកើតមានឡើងមុនពេលលោកអ្នកបានទទួល ឬ ជ្រើសរើសពាក្យសម្ងាត់ (ដោយរួមមានទាំងពាក្យសម្ងាត់មួយដែលបានចេញឲ្យសារជាថ្មី)

(d) បណ្តាលមកពីប្រតិបត្តិការមួយគ្មានការអនុញ្ញាតដែលកើតមានឡើងក្រោយពីលោកអ្នកបានជូនដំណឹងដល់ធនាគារ ANZ Royal ថា សុវត្ថិភាពពាក្យសម្ងាត់របស់លោកអ្នក ត្រូវបានគេរំលោភបំពាន

(e) បណ្តាលមកពីប្រតិបត្តិការដូចគ្នាកំពុងត្រូវបានដកចេញដោយមិនត្រឹមត្រូវលើសពីមួយម្តងពីគណនីតែមួយ

(f) បណ្តាលមកពីប្រតិបត្តិការមួយដែលគ្មានការអនុញ្ញាត ហើយប្រសិនបើវាច្បាស់ថា លោកអ្នកមិនបានរួមចំណែកដល់ការខាតបង់ទាំងនោះ។

### 1.15.2 ដំណាក់កាលដែលម្ចាស់គណនីមានទំនួលខុសត្រូវ

ម្ចាស់គណនី មានទំនួលខុសត្រូវចំពោះការខាតបង់ទឹកប្រាក់ពិតប្រាកដ ឬ ការទប់ស្កាត់ព័ត៌មានតាមរយៈការប្រើប្រាស់ណាមួយដែលគ្មានការអនុញ្ញាតលើម្ចាស់គណនី ប្រសិនបើម្ចាស់គណនី ឬ តំណាងម្ចាស់គណនីដែល មានការអនុញ្ញាតរបស់ខ្លួន បានរួមចំណែកចំពោះការប្រើប្រាស់ដែលគ្មានការអនុញ្ញាត:

(a) តាមរយៈការក្លែងបន្លំ ឬ ធ្វេសប្រហែសរបស់លោកអ្នក

(b) តាមរយៈការបើកចំហអោយដឹងដោយស្ម័គ្រចិត្តនូវពាក្យសម្ងាត់របស់លោកអ្នកទៅឲ្យអ្នកណាម្នាក់ ដោយរួមទាំងសមាជិកក្រុមគ្រួសារ ឬ មិត្តភ័ក្រ្តផងដែរ

(c) តាមរយៈការរក្សាការកត់ត្រានៃពាក្យសម្ងាត់ (ដោយមិនមានចេតនាសមស្របណាមួយចំពោះការបន្លំនេះ)

- ជាមួយនឹងអត្តលេខរបស់អ្នកប្រើប្រាស់
- លើអត្ថបទណាមួយដែលធ្វើឡើងជាមួយនឹងអត្តលេខសម្រាប់អ្នកប្រើប្រាស់ ឬ
- ដែលអាចនឹងបាត់ ឬ ទទួលរងការលួចយកនៅពេលជាមួយគ្នាដូចអត្តលេខរបស់អ្នកប្រើប្រាស់ដែរ

(d) តាមរយៈការជ្រើសរើសយកពាក្យសម្ងាត់មួយដែលគេងាយស្រួលស្គាល់ មានដូចជា ថ្ងៃខែឆ្នាំកំណើត លេខចុះបញ្ជីរថយន្ត លេខទូរស័ព្ទ ឬ ឈ្មោះរបស់លោកអ្នក

(e) តាមរយៈការប្រើប្រាស់ពាក្យសម្ងាត់ដូចគ្នាសម្រាប់គោលបំណងផ្សេងៗទៀត ដោយរួមមានគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតផងដែរ

(f) តាមរយៈសកម្មភាពដោយភាពធ្វេសប្រហែសខ្លាំងចំពោះពាក្យសម្ងាត់ ឬ អត្តលេខក្នុងលក្ខណៈមិនធានាបាននូវសុវត្ថិភាពចំពោះពាក្យសម្ងាត់ ឬ អត្តលេខរបស់លោកអ្នក និង បញ្ហាការខកខានមិនបានអនុវត្តតាមគោលការណ៍ណែនាំលើបញ្ហាសុវត្ថិភាពរបស់ធនាគារ ANZ Royal។

ប្រសិនបើ ក្រោយពីលោកអ្នកបានដឹងអំពីការបាត់បង់ ការលួច ឬ រំលោភបំពានលើបញ្ហាសុវត្ថិភាព ឬ ពាក្យសម្ងាត់របស់លោកអ្នក ហើយលោកអ្នក មានការយឺតយាវដោយគ្មានហេតុផលក្នុងការជូនដំណឹងដល់ធនាគារ ANZ Royal នោះ ម្ចាស់គណនីត្រូវទទួលខុសត្រូវចំពោះការខូចខាតជាក់ស្តែងដែលបានកើតមានឡើងក្នុងរវាង:

(a) ពេលដែលលោកអ្នកដឹងដំបូងអំពីព្រឹត្តិការណ៍ទាំងឡាយណាដែលមានរៀបរាប់ខាងលើនេះ និង

(b) ពេលដែលធនាគារ ANZ Royal បានជ្រាបពិតប្រាកដអំពីព្រឹត្តិការណ៍ដែលពាក់ព័ន្ធ។

ប៉ុន្តែម្ចាស់គណនី នឹងមិនទទួលខុសត្រូវចំពោះការខូចខាតជាក់ស្តែងនោះទេ:

(a) ប្រតិបត្តិការកើតមាននៅថ្ងៃណាមួយដែលមានកម្រិតចំនួនទឹកប្រាក់ លើសពីប្រតិបត្តិការប្រចាំថ្ងៃដែលអាចអនុវត្តបាន (ប្រសិនបើមាន)

(b) ក្នុងករណីដែលលើសពីសមតុល្យនៃគណនីដែលពាក់ព័ន្ធ ដែលមានជាអាទិ៍: កម្រិតចំនួនទឹកប្រាក់ឥណទានដែលបានព្រមព្រៀងណាមួយ

(c) ត្រង់ចំណុចដែលធនាគារ ANZ Royal បានព្រមព្រៀងថា គណនីមិនអាចទទួលបានលទ្ធភាពប្រើប្រាស់ តាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតឬ

(d) ជាលទ្ធផលនៃការប្រព្រឹត្តដែលធនាគារ ANZ Royal អនុញ្ញាតច្បាស់លាស់ឲ្យលោកអ្នកចូលរួម ឬ ការខូចខាតដែលបានកើតមានឡើងបណ្តាលមកពីការបើកចំហ ការកត់ត្រា ឬ រក្សាទុកពាក្យសម្ងាត់លោកអ្នកតាមវិធីដែល ធនាគារ ANZ Royal តម្រូវ និងណែនាំអោយធ្វើសម្រាប់គោលបំណងដែលលោកអ្នកប្រើប្រាស់សេវាកម្ម ចូលប្រើគណនីដោយផ្ទាល់ ឬ ដោយប្រយោលដែលបានផ្សព្វផ្សាយ យល់ព្រម ឬ អនុញ្ញាតដោយធនាគារ ANZ Royal។

ប្រសិនបើវា មិនច្បាស់ថាតើលោកអ្នកបានចូលរួមចំណែកចំពោះការបាត់បង់ ដែលបណ្តាលដោយប្រតិបត្តិការមួយដែលគ្មានការអនុញ្ញាត និងនៅកន្លែងណាដែលគេត្រូវការពាក្យសម្ងាត់ ដើម្បីបំពេញប្រតិបត្តិការដែលគ្មានការអនុញ្ញាតនោះ ម្ចាស់គណនីមានទំនួលខុសត្រូវតិចតួចចំពោះបញ្ហាខាងក្រោមនេះ៖

(a) ការខាតបង់ជាក់ស្តែងនៅពេលដែលធនាគារ ANZ Royal ទទួលបានការជូនដំណឹងមកថាបញ្ហាសុវត្ថិភាពពាក្យសម្ងាត់ត្រូវបានគេរំលោភបំពាន (ប៉ុន្តែមិនមែនការខូចខាតណាមួយដែលបានកើតមានឡើង នៅថ្ងៃណាមួយ ប្រសិនបើចំនួនទឹកប្រាក់ធំជាងកម្រិតចំនួនទឹកប្រាក់ប្រតិបត្តិការប្រចាំថ្ងៃ (ប្រសិនបើមាន)) ឬ

(b) សមតុល្យគណនី រួមមានទាំងឥណទាន ដែលបានរៀបចំជាមុន ណាមួយ ដែល តម្លៃជាទឹកប្រាក់ត្រូវបានគេផ្ទេរនៅក្នុងប្រតិបត្តិការដែលគ្មានការអនុញ្ញាតនេះ។

## 1.16 ការបំពេញមុខងារមិនប្រក្រតីនៃប្រព័ន្ធកម្មវិធី

ធនាគារ ANZ Royal មិនតំណាង ឬ ធានាថា រាល់ការចូលទៅកាន់គេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនឹងមិនទទួលរងនូវការរំខានណាមួយនោះទេ។ ក្រៅពីពេលវេលាអាក់ខាន តាមកាលវិភាគ ដែលធនាគារ ANZ Royal បានជូនដំណឹងដល់លោកអ្នក ម្តងម្កាលនោះ លោកអ្នកត្រូវទទួលស្គាល់ថា សេវាកម្មធនាគារ ANZ Royal តាម ប្រព័ន្ធអ៊ីនធឺណែត អាចនឹងទទួលរងផលប៉ះពាល់ដោយការរអាក់រអួល កំហុស ឬ ការពន្យារនានា។ រាល់ការរអាក់រអួល កំហុសឆ្គង ឬ ការពន្យារពេលទាំងនេះ អាចបណ្តាលមកពីកត្តានានា មានជាអាទិ៍ (តែមិនកំណត់)៖ បញ្ហាលំបាកផ្នែកបច្ចេកទេសជាមួយនឹងការបំពេញមុខងារ ឬប្រតិបត្តិការរបស់ ធនាគារ ANZ Royal ឬ ដោយប្រព័ន្ធ Software របស់បុគ្គលណាមួយ បរិក្ខារ ឬប្រព័ន្ធ ការលំបាកលើផ្នែកចរាចរណ៍ ឬ បច្ចេកទេសជាមួយនឹងប្រព័ន្ធអ៊ីនធឺណែត ឬ ការអាក់ខាននៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដូចជាការខូចបណ្តាញខ្សែទូរស័ព្ទ ឬ ការរំខានក្នុងផ្នែកប្រព័ន្ធផ្តល់សញ្ញាឌីជីថល។

ធនាគារ ANZ Royal មានទំនួលខុសត្រូវចំពោះម្ចាស់គណនីសំរាប់ការបាត់បង់ណាមួយ ដែលបណ្តាលមកពីការអាក់ខាននៃប្រព័ន្ធកម្មវិធីរបស់ធនាគារ ANZ Royal និងបរិក្ខារដែលត្រូវបញ្ចប់ប្រតិបត្តិការទទួលដោយប្រព័ន្ធ និងបរិក្ខាររបស់ ធនាគារ ANZ Royal ដោយយោងទៅតាមសេចក្តីណែនាំនានារបស់លោកអ្នក។ ទោះជាយ៉ាងណាក៏ដោយបើលោកអ្នកបានដឹង ឬ គួរ តែបានដឹងថា ប្រព័ន្ធកម្មវិធី និងបរិក្ខាររបស់ធនាគារ ANZ Royal មិន អាចប្រើប្រាស់ ឬ តំណើការមិនប្រក្រតីន ទំនួលខុសត្រូវរបស់ធនាគារ ANZ Royal នឹងត្រូវកម្រិតអោយមានការកែតម្រូវកំហុសក្នុង គណនី និង ការសងចំពោះបន្ទុក ឬថ្លៃចំណាយនានាដែលបណ្តាលមកពីមូលហេតុនោះ។

ម្ចាស់គណនី មានទំនួលខុសត្រូវសម្រាប់ភាពត្រឹមត្រូវ និង ពេញលេញលើ ខ្លឹមសារដែលលោកអ្នកបានបញ្ចូល ឬ ដាក់ទិន្នន័យទៅកាន់គេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ធនាគារ ANZ Royal មិនទទួលខុសត្រូវសម្រាប់ភាពមិនត្រឹមត្រូវ ឬ មិនពេញលេញនៅក្នុងការ បញ្ចូល ឬ ដាក់បញ្ចូលទិន្នន័យដោយលោកអ្នកផ្ទាល់នោះទេ។ កំណត់ត្រារបស់ធនាគារ ANZ Royal អំពីឯកសារ និង ទិន្នន័យនានាដែលត្រូវបានគេដាក់បញ្ចូល ឬ បង្ហោះនោះ ត្រូវមានការបញ្ជាក់នឹងយល់ព្រមជាចុងក្រោយ។

## 1.17 ករណីប្រធានស័ក្តិ និង ការអាក់ខានតាម កាលវិភាគ

ធនាគារ ANZ Royal នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតណាមួយដែលកើតឡើងដោយសារលោកអ្នកទេ ប្រសិនបើការខូចខាតនោះកើតចេញពីបញ្ហាដែលចាត់ទុកជាករណីប្រធានស័ក្តិ ដោយរួមបញ្ចូលទាំងរយៈពេលអាក់ខានតាមកំណត់កាលវិភាគផងដែរ។

## 1.18 សុវត្ថិភាពនៃសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត

### កិច្ចព្យាយាមរបស់ធនាគារ ANZ Royal

ធនាគារ ANZ Royal នឹងប្រើប្រាស់វិធានការដូចតទៅនេះ ដែលខ្លួនគិតថាសមហេតុផលដើម្បីជួយធានាដល់ សុវត្ថិភាពរបស់គេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ធនាគារ ANZ Royal ឬ ភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់វិធានការ សុវត្ថិភាពមួយចំនួន (ដោយរួមមាន: កម្មវិធីសុវត្ថិភាព (firewalls) និង data encryption (128 bit Secure Sockets Layer (SSL) protocol ជួយផ្តល់បណ្តាញសុវត្ថិភាពសម្រាប់ប្រតិបត្តិការតាមអ៊ីនធឺណែតរបស់លោកអ្នក)។

ធនាគារ ANZ Royal មិនអាចធានាបានទេថា ការបញ្ជូនទិន្នន័យណាមួយលើប្រព័ន្ធអ៊ីនធឺណែតនោះ មានសុវត្ថិភាពពេលលេញទាំងស្រុងនោះទេ។

តាមសំណើ និង ការប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនោះ លោកអ្នកយល់ព្រមចំពោះការប្រើប្រាស់ទិន្នន័យដែលបានផ្តល់ឲ្យធនាគារ ANZ Royal សម្រាប់គោលបំណងនៃការផ្តល់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ហើយលោកអ្នកទទួលស្គាល់ថាទិន្នន័យដែលបានផ្តល់ឲ្យធនាគារ ANZ Royal នោះអាចនឹងទទួលបានការដាក់លេខកូដទិន្នន័យឌីជីថលបញ្ជូន និង រក្សាទុកដោយធនាគារ ANZ Royal សមាជិក ANZ Royal Bank Group ឬ ភ្នាក់ងារធនាគារ ANZ Royal ឬ សមាជិក ANZ Royal Bank Group (នៅព្រះរាជាណាចក្រកម្ពុជា អូស្ត្រាលី ឬ កន្លែងផ្សេងទៀត ប្រសិនបើច្បាប់មិនហាមឃាត់) ហើយលោកអ្នកក៏ទទួលស្គាល់ថា ធនាគារ ANZ Royal នឹងមិនទទួលខុសត្រូវទាក់ទងនឹងទិន្នន័យប្រភេទនេះទេ លើកលែងតែមានច្បាប់ចែងផ្ទុយពីនេះ។

### ទំនួលខុសត្រូវរបស់លោកអ្នកចំពោះ កុំព្យូទ័រផ្ទាល់ខ្លួន (PC)

លោកអ្នក មានទំនួលខុសត្រូវទាំងស្រុងលើការប្រឆាំងមេរោគ និង សុវត្ថិភាពលើកុំព្យូទ័រផ្ទាល់ខ្លួនរបស់លោកអ្នក និង តំណាងប្រើប្រាស់ទាំងអស់របស់ខ្លួន ដោយរួមទាំងអ្នកប្រតិបត្តិការក្រុមហ៊ុន ដើម្បីទប់ស្កាត់ការចូលតាមគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតដោយគ្មានការអនុញ្ញាត លើ រាល់ប្រតិបត្តិការ និង គណនីរបស់លោកអ្នក។ លោកអ្នក មានទំនួលខុសត្រូវលើខ្លួនឯងផ្ទាល់ សម្រាប់ការធានាឲ្យបានថា រាល់ការភ្ជាប់ដែលសំខាន់ចាំបាច់ទាំងអស់ ដែលមានដូចជា ឧបករណ៍ និង កម្មវិធីនានាសម្រាប់កុំព្យូទ័រផ្ទាល់ខ្លួន បណ្តាញទូរស័ព្ទដែលមានសុវត្ថិភាព ចរន្តអគ្គិសនី និង ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណែតដែលមានសុវត្ថិភាព អាចរកបានដើម្បីបង្កលទ្ធភាពឲ្យលោកអ្នកបានប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

## 1.19 ការទប់ស្កាត់ការលាងប្រាក់ និង បទល្មើសផ្សេងៗទៀត

ដោយការទទួលយកលក្ខខណ្ឌប្រើប្រាស់អស់ទាំងនេះ លោកអ្នកយល់ព្រមជាមួយនឹងធនាគារ ANZ Royal អាចនឹងពន្យារពេល បង្ខាំងទុក ឬ បដិសេធដោះស្រាយនូវប្រតិបត្តិការណាមួយដោយមិនមានការទទួលខុសត្រូវ ប្រសិនបើធនាគារ ANZ Royal សង្ស័យថា៖

(a) ប្រតិបត្តិការនេះ អាចនឹងរំលោភបំពានដល់ច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជា ឬ ប្រទេសណាមួយផ្សេងទៀត

(b) ប្រតិបត្តិការនេះ អាចមានពាក់ព័ន្ធដោយផ្ទាល់ និង ប្រយោល ដល់ការបន្ត ឬ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការប្រព្រឹត្ត ខុសច្បាប់។

លោកអ្នក ត្រូវតែផ្តល់នូវរាល់ព័ត៌មានទាំងអស់ដល់ធនាគារ ANZ Royal ដែលមានតម្រូវការចាំបាច់សមស្របដើម្បីគ្រប់គ្រងលើបញ្ហា លាងប្រាក់ ហានិភ័យអំពីការផ្តល់ហិរញ្ញប្បទានសម្រាប់អំពើភេរវកម្ម និង ហានិភ័យអំពីទណ្ឌកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្ម ឬ អនុលោម តាមច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជា ឬ ប្រទេសណាមួយផ្សេងទៀត ឬ ដើម្បីអនុលោមតាមបម្រាមនៃប្រទេសមួយផ្សេងទៀត ដែលអាចអនុវត្តបានជាមួយនឹងធនាគារ ANZ Royal ដោយគោរពតាមប្រតិបត្តិការណាមួយ ហើយលោកអ្នកយល់ព្រមថា ធនាគារ ANZ Royal អាចនឹងបើកចំហនូវព័ត៌មានណាមួយដែលពាក់ព័ន្ធនឹងលោកអ្នក ទៅដល់:

(a) ស្ថាប័ននីតប្រតិបត្តិ និង ទីភ្នាក់ងារមានអំណាចធ្វើបទបញ្ជា ឬ តុលាការដែលចាំបាច់តាមតម្រូវការច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជា ឬ ប្រទេសផ្សេងទៀត

(b) ធនាគារដៃគូរបស់ ANZ Royal ណាមួយដើម្បីធ្វើការចំណាយទូទាត់សម្រាប់គោលបំណងគោរពតាមច្បាប់ណាមួយ។

ប្រសិនបើលោកអ្នក មិនបានបើកចំហថា លោកអ្នកកំពុងប្រតិបត្តិជាអ្នកដែលមានសមត្ថភាពគួរអោយទុកចិត្ត ឬ ជំនួសអោយមនុស្ស ណាម្នាក់ លោកអ្នកធានាថា លោកអ្នកកំពុងដើរតួបំពេញមុខងារក្នុងនាមខ្លួននៅក្នុងការយល់ព្រមតាម លក្ខខណ្ឌប្រើប្រាស់ទាំងនេះ។

លោកអ្នក ប្រកាស បញ្ជាក់ យល់ព្រម និង ទទួលរ៉ាប់រងចំពោះធនាគារ ANZ Royal ថា ការទូទាត់ប្រាក់ ដោយធនាគារ ANZ Royal ដោយយោងតាមសេចក្តីណែនាំរបស់លោកអ្នកនោះ នឹងមិនរំលោភបំពានលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ ដែនសមត្ថកិច្ចណាមួយផ្សេងទៀតឡើយ។

## 1.20 ការបញ្ឈប់ និង ព្យួរចោល

### ការបញ្ឈប់លទ្ធភាពប្រើប្រាស់ ដោយម្ចាស់គណនី

ម្ចាស់គណនី អាចនឹងលុបចោលលទ្ធភាពប្រើប្រាស់នៃម្ចាស់គណនីលើគេហទំព័រសេវាកម្មធនាគារ ANZ Royal (ឬ បដិសេធចំពោះសិទ្ធិអំណាចនៃតំណាងអ្នកប្រើប្រាស់ ចំពោះលទ្ធភាពប្រើប្រាស់នូវគណនីរបស់ម្ចាស់គណនីដែលប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត) នៅពេលណាមួយ ក៏បានតាមរយៈការជូនដំណឹងជាផ្លូវការមួយដល់សាខាធនាគារ ANZ Royal ឬ បំពេញទម្រង់បែបបទប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតដើម្បីការលុបចោលការប្រើប្រាស់ ហើយដាក់សុំនៅតាមសាខាធនាគារ ANZ Royal នៅតាមមូលដ្ឋានរបស់លោកអ្នក។

### ការបញ្ឈប់ ឬ ព្យួរចោលលទ្ធភាពប្រើប្រាស់

ធនាគារ ANZ Royal អាចនឹងបញ្ឈប់លទ្ធភាពប្រើប្រាស់របស់លោកអ្នកចំពោះសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនៅពេលណាមួយក៏បាន តាមរយៈការជូនដំណឹងលោកអ្នកជាលាយលក្ខអក្សរ (ដែលអាចនឹងរួមមាននូវការជូនដំណឹងដែលបានផ្តល់ជូនលោកអ្នក នៅពេលដែលលោកអ្នកចូលប្រើប្រាស់គេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត)។ ធនាគារ ANZ Royal អាចនឹងដកហូតវិញ ឬ បដិសេធចោលនូវលទ្ធភាពប្រើប្រាស់ចំពោះសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ឬ ផ្នែកណាមួយនៃសេវាកម្មនេះ ដោយមិនចាំបាច់មានការជូនដំណឹងជាមុនចំពោះលោកអ្នកសម្រាប់ហេតុផលសន្តិសុខ ឬ គុណភាពសេវាកម្ម

ធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។ ធនាគារ ANZ Royal នឹងមិនអនុវត្តបញ្ជានេះ ដោយមិនមានហេតុផលសមស្របដែលមានជាអាទិ៍:

(a) ធនាគារ ANZ Royal កំពុងសង្ស័យថា លោកអ្នកកំពុងក្លែងបន្លំ ឬ ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តមិនត្រឹមត្រូវ

(b) ធនាគារ ANZ Royal កំពុងសង្ស័យថា ភាគីទីបីបានប្រើប្រាស់ដោយការក្លែងបន្លំ ឬ មានចេតនាប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ជាមួយនឹងអត្តសញ្ញាណ ពាក្យសម្ងាត់ ឧបករណ៍ សុវត្ថិភាព និង/ឬ កូដកម្មវិធីឧបករណ៍ សុវត្ថិភាព

(c) ប្រសិនបើ ឯកសារម្ចាស់គណនី ឬ ឯកសារម្ចាស់របស់ម្ចាស់បំណុល ផ្ទុយនឹងម្ចាស់គណនី គឺសំណើសំរាប់ការក្ស័យធន ដែលនាំដល់ការបិទ ឬរុះរើរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ ឬ

(d) ដែលតម្រូវដោយច្បាប់។

ក្នុងករណីដែលធនាគារ ANZ Royal ប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយបានពិនិត្យនៅក្នុងកថាខ័ណ្ឌនេះ ធនាគារនឹងមិនទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលម្ចាស់គណនី អាចនឹងមានបញ្ហា ឬ បានរងគ្រោះដែលកើតចេញពីបញ្ហានេះឡើយ។

## តើមានអ្វីកើតឡើង ប្រសិនបើការបញ្ឈប់ ឬ ព្យួរលទ្ធភាពប្រើប្រាស់កើតមានឡើង?

ក្នុងករណីដែលលទ្ធភាពប្រើប្រាស់របស់លោកអ្នកចំពោះសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ត្រូវបាន:

(a) បញ្ឈប់ ប្រតិបត្តិការទាំងឡាយណាដែលត្រូវបានដំណើរការដោះស្រាយ ដោយរួមទាំង ការផ្ទេរបន្តបន្ទាប់តាម កាលវិភាគសម្រាប់ពេលខាងមុខ នឹងត្រូវគេលុបចោលទាំងអស់

(b) គេព្យួរចោល ប្រតិបត្តិការណាមួយដែលមិនបានដំណើរការដោះស្រាយ ដោយរួមមានទាំងការផ្ទេរបន្តបន្ទាប់តាម កាលវិភាគសម្រាប់ពេលខាងមុខ នឹងត្រូវបានគេដោះស្រាយ ដោយអាស្រ័យលើទឹកប្រាក់ដែល មាននៅក្នុងគណនីផ្គត់ផ្គង់សាច់ប្រាក់។

## 1.21 ដំណោះស្រាយកំហុស ឬ វិវាទ

លោកអ្នក ត្រូវតែទទួលទុកនូវកំណត់ហេតុសេចក្តីណែនាំដែលបានបំពេញដែលបានធ្វើតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត និងបន្តកែខែភាពច្បាស់លាស់ និង ត្រឹមត្រូវនៃកំណត់ហេតុប្រភេទនេះ។ ធនាគារ ANZ Royal នឹងរក្សាទុកនូវរាល់កំណត់ហេតុដែលបានធ្វើឡើងតាមរយៈគេហទំព័រសេវាកម្មធនាគារ ANZ Royal ដូចដែលតម្រូវដោយច្បាប់ និង យោងតាមគោលនយោបាយរក្សាទុកឯកសាររបស់ធនាគារ ANZ Royal។

ម្ចាស់គណនី ត្រូវតែត្រួតពិនិត្យមើលកំណត់ហេតុសម្រាប់ម្ចាស់គណនីឲ្យបានច្បាស់លាស់ និង ភ្លាមៗ។ ប្រសិនបើម្ចាស់គណនី ជឿជាក់ថា មានកំហុសមួយបានកើតមានឡើងនៅក្នុងប្រតិបត្តិការណាមួយ ឬ មានប្រតិបត្តិការដែលគ្មានការអនុញ្ញាតនោះ ម្ចាស់គណនីត្រូវតែទាក់ទងមកមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ឬ ជួបទំនាក់ទំនងផ្ទាល់ជាមួយនឹងសាខាធនាគារ ANZ Royalដែលនៅជិតអ្នកបំផុងភ្លាមៗ។

ដើម្បីជួយដល់ការស៊ើបអង្កេតរបស់ធនាគារ ANZ Royal ម្ចាស់គណនី នឹងចាំបាច់ត្រូវផ្តល់នូវព័ត៌មានដូចខាងក្រោមនេះ៖

- ឈ្មោះ អាសយដ្ឋាន និង ព័ត៌មានលម្អិតអំពីគណនីរបស់ម្ចាស់គណនី
- លម្អិតអំពីប្រតិបត្តិការដែលមានចង្ងល់
- ចំនួនទឹកប្រាក់ដែលសង្ស័យថាមានកំហុស ឬ វិវាទ ឬ ជាប្រតិបត្តិការដែលគ្មានការអនុញ្ញាត។

លើសពីនេះ ធនាគារ ANZ Royal អាចនឹងសាកសួរម្ចាស់គណនីអោយផ្តល់នូវព័ត៌មានបន្ថែមទៀត។

ប្រសិនបើលោកអ្នក ប្រាប់ធនាគារ ANZ អំពីកំហុសដែលសង្ស័យ ឬ ប្រតិបត្តិការដែលមានបញ្ហាដោយផ្ទាល់មាត់នោះ ធនាគារ ANZ Royal អាចនឹងស្នើសុំឲ្យម្ចាស់គណនីផ្ញើឲ្យធនាគារ ANZ Royal នូវព័ត៌មានលម្អិតអំពីការតវ៉ានេះជាលាយលក្ខអក្សរ។ ប៉ុន្តែទង្វើនេះនឹងមិនពន្យារពេលដល់ការចាប់ផ្តើមស៊ើបអង្កេតរបស់ធនាគារ ANZ Royal បើសិនជា លោកអ្នកបានផ្តល់ព័ត៌មានដូចដែលមានរៀបរាប់ខាងលើនេះ។

ប្រសិនបើធនាគារ ANZ Royal មិនអាចដោះស្រាយបញ្ហាវិវាទនេះភ្លាមៗតាមបំណងលោកអ្នកនោះទេ ធនាគារ ANZ Royal នឹងផ្តល់ជូនម្ចាស់គណនីនូវសេចក្តីជូនដំណឹងជាលាយលក្ខអក្សរដែលបង្ហាញពីដំណាក់កាលផ្សេងៗ ដែលធនាគារ ANZ Royal នឹងធ្វើការស៊ើបអង្កេត និង ដោះស្រាយវិវាទនេះ។

## 1.22 ថ្លៃឈ្នួលផ្សេងៗ

នៅពេលលោកអ្នក ប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ដើម្បីធ្វើប្រតិបត្តិការមួយចំនួយធនាគារ ANZ Royal អាចនឹងកំណត់ឲ្យបង់ថ្លៃផ្សេងៗ។ លោកអ្នក ត្រូវយល់ព្រមចំណាយថ្លៃឈ្នួលផ្សេងៗ ហើយយល់ព្រមឲ្យធនាគារ ANZ កាត់ថ្លៃឈ្នួលសេវាដោយផ្ទាល់ពីគណនីផ្គត់ផ្គង់សាច់ប្រាក់របស់លោកអ្នក ឬ ក៏កាត់ពី គណនីអ្នកទទួល (នៅចំណុចដែលអាចអនុវត្តបាន)។ ថ្លៃឈ្នួលទាំងនេះ អាចនឹងធ្វើកែប្រែដោយធនាគារ ANZ Royal ជាបន្តបន្ទាប់។ លម្អិតពេញលេញអំពីថ្លៃឈ្នួលបច្ចុប្បន្ន អាចរកបាននៅតាមបណ្តាសាខាធនាគារ ANZ Royal ដែលនៅជិតបំផុតនឹងលោកអ្នក។

## 1.23 បម្រែបម្រួលនៃលក្ខខណ្ឌប្រើប្រាស់ និង ការយកថ្លៃឈ្នួលសេវាផ្សេងៗ

ធនាគារ ANZ Royal អាចនឹងធ្វើការកែប្រែ លក្ខខណ្ឌ និង ការយកថ្លៃឈ្នួលសេវាទាំងនេះសម្រាប់ការប្រើប្រាស់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ដែលអាចអនុវត្តបានចំពោះសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ក្នុងករណីដែលមានតម្រូវការចាំបាច់ដោយច្បាប់ ឬ លើសពីនេះ។

ធនាគារ ANZ Royal អាចនឹងផ្លាស់ប្តូរលក្ខខណ្ឌប្រើប្រាស់ទាំងនេះ និងថ្លៃឈ្នួលសេវាកម្មដែលអាចអនុវត្តបានចំពោះសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតនៅពេលណាមួយ ដោយធ្វើការជូនដំណឹងដល់លោកអ្នកអំពីការផ្លាស់ប្តូរនេះ មិនលើសពីរយៈពេល 30ថ្ងៃ នៅមុនពេលចាប់មានប្រសិទ្ធភាព តាមមធ្យោបាយដូចខាងក្រោមនេះ៖

- ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយនឹងលោកអ្នក (ឧទាហរណ៍: ដោយការជូនដំណឹងនៅលើរបាយការណ៍គណនីរបស់លោកអ្នក ឬតាមរយៈការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណែត)

- សេចក្តីជូនដំណឹងដែលមានបិទផ្សាយនៅតាមបណ្តាសាខាធនាគារ ANZ Royal ឬ លើគេហទំព័ររបស់ធនាគារ ANZ Royal ឬ

- ការផ្សព្វផ្សាយពាណិជ្ជកម្មដែលភាគច្រើនតាមរយៈកាសែតប្រចាំថ្ងៃ ឬ កាសែតក្នុងស្រុកនៅព្រះរាជាណាចក្រកម្ពុជា។

លោកអ្នក នឹងទទួលបានការជូនដំណឹងភ្លាមៗរួចហើយ ក្រោយពីបិទផ្សាយ ឬ ការផ្សព្វផ្សាយពាណិជ្ជកម្មប្រភេទនេះ។

ការបន្តប្រើប្រាស់ណាមួយនៃសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត ក្រោយពីការបញ្ចប់រយៈពេលជូនដំណឹងដោយលោកអ្នក នឹងត្រូវរួមជាមួយការទទួលយកនូវបំរែបំរួលរបស់លោកអ្នក។

## 1.24 សំណង

ចំពោះវិសាលភាពដែលអនុញ្ញាតដោយច្បាប់ ម្ចាស់គណនីត្រូវយល់ព្រមផ្តល់សំណងឲ្យធនាគារ ANZ Royal ដោយទូទាត់ទៅនឹងការខូចខាត ឬបាត់បង់ដែលធនាគារ ANZ Royal អាចនឹងត្រូវទទួលរងដោយសារការទាមទារ ឬ ចំណាត់ការណាមួយដែលគេធ្វើឡើងចំពោះធនាគារ ANZ Royal ដែលនឹងលេចឡើងដោយផ្ទាល់ ឬ ដោយប្រយោល ដោយសារម្ចាស់គណនី និង/ឬ តំណាងអ្នកប្រើប្រាស់រួមមានទាំងអ្នកធ្វើប្រតិបត្តិការក្រុមហ៊ុនផងដែរ:

- មិនបានអង្កេតមើលកាតព្វកិច្ចរបស់ខ្លួនក្រោមលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ឬ

- បានធ្វើដោយធ្វេសប្រហែស ឬ ដោយបន្លំពាក់ព័ន្ធនឹងលក្ខខណ្ឌប្រើប្រាស់ទាំងនេះ។

## 1.25 ច្បាប់គ្រប់គ្រង

លក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ត្រូវបាន គ្រប់គ្រង និងត្រូវបានបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ លោកអ្នក និង ធនាគារ ANZ យល់ព្រមដាក់សុំយុត្តាធិការដោយឡែករបស់តុលាការដែលមានដែនសមត្ថកិច្ចស្ថិតក្រោមច្បាប់នោះ។

## 1.26 ការបើកចំហឯកជនភាព និង ការសម្ងាត់

ពេលលោកអ្នកដោះស្រាយជាមួយនឹងធនាគារ ANZ Royal ធនាគារប្រាកដជានឹងប្រមូល និង ប្រើប្រាស់ព័ត៌មានមួយចំនួនរបស់លោកអ្នក ដែលមានជាអាទិ៍: លម្អិតអំពីប្រតិបត្តិការ ស្ថានភាពហិរញ្ញវត្ថុរបស់លោកអ្នក ទំនាក់ទំនងគណនីជាមួយនឹងធនាគារ ANZ Royal និង/ឬ គណនីមួយឬច្រើនរបស់លោកអ្នក (ជារួមហៅថា ជា 'ព័ត៌មាន')។ ធនាគារ ANZ Royal សូមពន្យល់ដូចខាងក្រោមនេះ អំពីពេលវេលា និងរបៀបរបបដែលធនាគារ ANZ Royal អាចនឹងប្រមូល និងប្រើប្រាស់ព័ត៌មានរបស់លោកអ្នក។

### ការប្រមូលព័ត៌មានរបស់លោកអ្នកដោយធនាគារ ANZ Royal

ចំពោះវិសាលភាពដែលអនុញ្ញាតដោយច្បាប់ ធនាគារ ANZ Royal អាចនឹងប្រមូលយកព័ត៌មានរបស់លោកអ្នក:

- ដើម្បីជួយនៅក្នុងការផ្តល់ព័ត៌មានអំពីផលិតផល ឬ សេវាកម្ម

- ដើម្បីពិនិត្យពិចារណាលើសំណើលោកអ្នកសម្រាប់ផលិតផល ឬ សេវាកម្ម

- ដើម្បីបង្កលទ្ធភាពឲ្យធនាគារ ANZ Royal ផ្តល់នូវផលិតផល ឬ សេវាកម្ម

- ដើម្បីជម្រាបជូនលោកអ្នកអំពីផលិផល ឬ សេវាកម្មទាំងឡាយដែលអាចនឹងមានចំណាប់អារម្មណ៍ចំពោះលោកអ្នក

- ដើម្បីបំពេញកិច្ចការរដ្ឋបាល និង ប្រតិបត្តិការផ្សេងៗទៀត (ដោយរួមមានទាំងការគ្រប់គ្រងលើបញ្ហាហានិភ័យ ការបង្កើតប្រព័ន្ធកម្មវិធីនិងសាកល្បងឲ្យប្រើប្រាស់ កំណត់កម្រិតឥណទាន ការបណ្តុះបណ្តាលបុគ្គលិក និងការស្រាវជ្រាវទីផ្សារ និង ការបំពេញបំណងអតិថិជន)

- ដើម្បីការពារ ឬ ស៊ើបអង្កេតករណីក្លែងបន្លំ ឬ ឧក្រិដ្ឋកម្មណាមួយ (ឬ ការសង្ស័យអំពីការក្លែងបន្លំ ឬ បទឧក្រិដ្ឋ) និង

- តាមតម្រូវការចាំបាច់ដោយច្បាប់នានាដែលពាក់ព័ន្ធ បញ្ញតិច្បាប់/បទបញ្ជា និង ប្រព័ន្ធទូទាត់ផ្នែកខាងក្រៅ បើទោះជានៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ។

## ការគ្មានព័ត៌មានដែលពាក់ព័ន្ធ

ប្រសិនបើលោកអ្នក មិនផ្តល់នូវព័ត៌មានមួយចំនួន ឬ ទាំងអស់ដែលបានស្នើសុំនោះទេ ធនាគារ ANZ Royal នឹងមិនអាចផ្តល់ជូនលោកអ្នកនូវផលិតផល ឬ សេវាកម្មណាមួយបានឡើយ។

## ការបើកចំហដោយធនាគារ ANZ Royal

ដោយអាស្រ័យលើកាតព្វកិច្ចជាទូទៅរបស់ធនាគារ ANZ Royal ចំពោះការសម្ងាត់សំដៅលើអតិថិជនរបស់ធនាគារ ANZ Royal និងចំពោះវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ជាមុន តាមការស្នើសុំប្រើប្រាស់និង/ឬ ការបន្តប្រើប្រាស់សេវាកម្មធនាគារ ANZ តាមប្រព័ន្ធអ៊ីនធឺណែតនោះ លោកអ្នកយល់ព្រមអនុញ្ញាតឲ្យ ធនាគារ ANZ Royal មានលទ្ធភាពប្រើប្រាស់ និង បើកចំហព័ត៌មានរបស់លោកអ្នកដល់៖

- សមាជិក ANZ Royal Bank Group ណាមួយ

- ការិយាល័យ សាខា អង្គភាពចម្រុះ ការិយាល័យរង បុគ្គលិក ឬ ភ្នាក់ងារជាសមាជិកធនាគារ ANZ Royal Bank Group ឬ ដល់សវនកឬ អ្នកប្រឹក្សាយោបល់ផ្នែកច្បាប់

- ទីភ្នាក់ងារធ្វើរបាយការណ៍ឥណទាន ឬ ទីភ្នាក់ងារប្រមូលឥណពន្ធ

- ក្រុមហ៊ុនផ្តល់ការងារបន្ត ភ្នាក់ងារ និង អ្នកម៉ៅការដែលធនាគារ ANZ Royal ឬ សមាជិក ANZ Royal Bank Group ណាមួយអនុញ្ញាតអោយអនុវត្ត ឬ ជួយបំពេញសកម្មភាព និង មុខងារធនាគារកិច្ចរបស់ខ្លួន ដោយរួមមានទាំងផ្នែកសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតផងដែរ

- អង្គការបញ្ញត្តិ ទីភ្នាក់ងាររដ្ឋាភិបាល ស្ថាប័ននីតិប្រតិបត្តិនិងតុលា ដែលនៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា

- ភាគីផ្សេងៗទៀតដែលធនាគារ ANZ Royal ទទួលបានការអនុញ្ញាត ឬ តម្រូវដោយច្បាប់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ឬ នៅប្រទេសមួយផ្សេងទៀតដើម្បីបើកចំហព័ត៌មានដល់

- ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត

- ភ្នាក់ងារនានារបស់លោកអ្នកដែលមានការអនុញ្ញាតត្រឹមត្រូវ ឬ អ្នកប្រតិបត្តិជំនួសលោកអ្នក អ្នកគ្រប់គ្រងធុរកិច្ច ឬ តំណាងផ្នែកច្បាប់

- បុគ្គលណាម្នាក់ដែលស្ថិតក្នុងការពិនិត្យមើលរបស់ធនាគារ ANZ Royal ការបើកចំហមានលក្ខណៈចាំបាច់ ឬ អាចចង់បានសម្រាប់គោលបំណងអនុញ្ញាតឲ្យធនាគារ ANZ Royal បំពេញកាតព្វកិច្ច និង ការអនុវត្តន៍របស់ខ្លួន នូវសិទ្ធិអំណាចក្រោមលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ

- បុគ្គលណាម្នាក់ដែលធនាគារ ANZ Royal នឹងគិតថាសមស្រប ក្នុងឆន្ទានុសិទ្ធិពេញលេញរបស់ខ្លួន។

ចំពោះវិសាលភាពដែលអនុញ្ញាតដោយច្បាប់ លោកអ្នក យល់ព្រមនិងទទួលស្គាល់បន្ថែមទៀតថា សមាជិក ANZ Group ណាមួយ អាចនឹងផ្ទេរនូវព័ត៌មានណាមួយខាងលើនេះទៅកាន់ភាគីណាមួយដែលទទួលបានការអនុញ្ញាតត្រឹមត្រូវឲ្យបើកចំហដូចគ្នាដែលយោងទៅតាមខ្លឹមសារដោយឡែកខាងលើនេះ ដែលទីកន្លែងអាជីវកម្មជាមូលដ្ឋានរបស់ភាគីប្រភេទនេះ គឺស្ថិតនៅក្រៅដែនសមត្ថកិច្ច ឬ សិទ្ធិអំណាចដែលលោកអ្នកស្ថិតនៅ ឬ ដែលប្រភេទនៃព័ត៌មាននេះនឹងត្រូវបានគេប្រមូល រក្សាទុក វិភាគ ឬ ប្រើប្រាស់ដោយភាគីនេះទាំងមូល ឬ ដោយផ្នែកនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

## លទ្ធភាពប្រើប្រាស់ព័ត៌មានរបស់លោកអ្នកដែលស្ថិតក្នុងបន្ទុករបស់ធនាគារ ANZ Royal

ចំពោះវិសាលភាពដែលអនុញ្ញាតដោយច្បាប់ លោកអ្នកអាចនឹងមានលទ្ធភាពប្រើប្រាស់ និងស្នើសុំកែប្រែព័ត៌មានរបស់លោកអ្នកនៅពេលណាមួយក៏បាន តាមរយៈការស្នើសុំនៅតាមសាខាធនាគារ ANZ Royal នៅក្នុងមូលដ្ឋាន របស់លោកអ្នក។

## 1.27 ការជូនដំណឹង និង ការឆ្លើយឆ្លងសំបុត្រ

ការឆ្លើយឆ្លងសំបុត្រ ការជូនដំណឹង ឬ ឯកសារផ្សេងៗទៀតដែលទាក់ទងនឹងសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែតដែលធនាគារ ANZ Royal ត្រូវតែជម្រាបជូនលោកអ្នកជាលាយលក្ខអក្សរ ធនាគារ ANZ Royal នឹងបង្កើតឲ្យមាននៅតាមបណ្តាសាខារបស់ខ្លួនសម្រាប់ការទៅយក ប្រសិនបើការរៀបចំជាពិសេសមួយមិនទទួលបានការព្រមព្រៀងឲ្យផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ ក្រុមហ៊ុនទទួលបញ្ញើរ ឲ្យយកទៅដាក់នៅអាសយដ្ឋានផ្ញើសំបុត្ររបស់គណនីគោលដែលបានកំណត់ឲ្យមានដោយលោកអ្នកផ្ទាល់។ លោកអ្នក នឹងត្រូវគេចាត់ទុកថាបានទទួលការឆ្លងឆ្លើយសំបុត្រ ឬ ការជូនដំណឹងប្រភេទនេះពីធនាគារ ANZ Royal:

- ក្នុងករណីការទៅយកពីតាមបណ្តាសាខាធនាគារ ANZ Royal របស់លោកអ្នក នៅថ្ងៃទីសាមសិប (30th) នៃថ្ងៃធ្វើការរបស់ធនាគារ ANZ Royal ដែលក្រោយកាលបរិច្ឆេទនេះ ការឆ្លងឆ្លើយសំបុត្រ ឬ ការជូនដំណឹងត្រូវបានធ្វើឲ្យមានសម្រាប់ការទៅយកពីតាមសាខាធនាគារ ANZ Royal របស់លោកអ្នក

- ក្នុងករណីផ្ញើតាមការិយាល័យប្រៃសណីយ ឬក្រុមហ៊ុនទទួលបញ្ញើរ នៅពេលទទួលបានការបញ្ជាក់អំពីឆ្លងឆ្លើយសំបុត្រ ឬ ការជូនដំណឹងត្រូវបានផ្តល់ដល់ភ្នាក់ងារប្រៃសណីយ ឬក្រុមហ៊ុនទទួលបញ្ញើរដោយលោកអ្នក។

## 1.28 ភាពមិនច្បាស់លាស់

នៅពេលមានភាពមិនច្បាស់លាស់ណាមួយរវាងភាសាអង់គ្លេស និង ភាសាខ្មែរនៃឯកសារនេះ ភាសាខ្មែរនឹងត្រូវមានភាពលុបលើចំពោះវិសាលភាពនៃភាពមិនច្បាស់លាស់នេះ។

## 1.29 កំណត់(ចាត់តាំង)ឲ្យបំពេញមុខងារ

ម្ចាស់គណនី អាចនឹងមិនឲ្យផ្ទេរ និង/ឬ កំណត់ឲ្យមាននូវសិទ្ធិណាមួយ ឬ ទាំងស្រុងឬដោយផ្នែករបស់ខ្លួនដែលមានរួមទាំងអត្ថប្រយោជន៍ និង/ឬ កាតព្វកិច្ចក្រោមលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ឬ ឯកសារណាមួយដែលទាក់ទងដោយគ្មានការយល់ព្រមជាលាយលក្ខអក្សរពីធនាគារ ANZ Royal បានឡើយ។

នៅពេលណាមួយ ធនាគារ ANZ Royal អាចនឹងផ្ទេរ និង/ឬ កំណត់ឲ្យមាននូវសិទ្ធិណាមួយ ឬ ទាំងស្រុងឬដោយផ្នែកដែលរួមមានដូចជាអត្ថប្រយោជន៍ និង/ឬ កាតព្វកិច្ចដែលស្ថិតក្រោមលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ឬ ឯកសារដែលទាក់ទងការិយាល័យរងរួមគ្នាមួយនៅតាមមូលដ្ឋានរបស់ធនាគារ ANZ Royal ក្នុងដែនសមត្ថកិច្ចដែលធនាគារ ANZ Royal ធ្វើប្រតិបត្តិការ ដោយគ្មានការយល់ព្រមរបស់លោកអ្នកបានឡើយ។ ដើម្បីរួមបញ្ចូលគ្នានូវការផ្ទេរប្រភេទនេះ និង/ឬ ការកំណត់ឲ្យមានកាតព្វកិច្ចនោះ ធនាគារ ANZ Royal ទទួលបានការអនុញ្ញាតឲ្យបើកចំហនូវព័ត៌មានដែលពាក់ព័ន្ធណាមួយឲ្យដល់ការិយាល័យរង ឬ ផ្នែកចម្រុះ ហើយលោកអ្នកយល់ព្រមទទួលយកចំណាត់ការទាំងនេះ និង ចុះហត្ថលេខាលើឯកសារនានាដែលធនាគារ ANZ Royal អាចនឹងចាំបាច់ត្រូវការយ៉ាងសមស្របដើម្បីបំពេញការយល់ព្រម ការទុកដាក់ឯកសារ ឬ បំពេញបែបបទចុះឈ្មោះដែលមានលក្ខណៈចាំបាច់សម្រាប់ការផ្ទេរ និង/ឬ កំណត់កាតព្វកិច្ចប្រភេទនេះ។

## 1.30 ចំណងជើង

ការប្រើប្រាស់ចំណងជើងផ្នែកនានា នៅក្នុងលក្ខខណ្ឌប្រើប្រាស់ទាំងនេះ ត្រូវបានគេបញ្ចូលសម្រាប់ភាពងាយស្រួល ដល់ការយោងគ្នានៃអត្ថន័យតែប៉ុណ្ណោះ និង មិនត្រូវមានការចាត់ទុកជាការបង្កើត ឬ បកស្រាយលើបញ្ញត្តិណាមួយនៃលក្ខខណ្ឌប្រើប្រាស់ទាំងនេះឡើយ។

## 1.31 ការបើកចំហផ្នែកទី APS222

**ធនាគារ ANZ Royal គឺជាក្រុមហ៊ុនសាខាមួយនៃធនាគារ Australia និង New Zealand Banking Group លីមីធីត (ANZBGL) ដែលបានបង្កើតឡើងនៅប្រទេស Australia។ ធនាគារ ANZ Royal បង្កើតនៅក្នុង ព្រះរាជាណាចក្រកម្ពុជាជាធនាគារ ដែលទទួលខុសត្រូវមានកម្រិត។ ធនាគារ ANZ Royal មិនមែនជាស្ថាប័នយកការតម្កល់ប្រាក់មួយដែលទទួលបានការអនុញ្ញាតក្នុងក្របខ័ណ្ឌច្បាប់នៃប្រទេសអូស្ត្រាលីឡើយ។ ប្រាក់តម្កល់ ឬ បំណុលនានា**

ANZ Royal Bank

ដែលមានជាមួយនឹងធនាគារ ANZ Royal មិនមែនជាការតម្កល់ប្រាក់ ឬ បំណុលរបស់ ANZBGL ហើយ ANZBGL មិនធានាដល់ការបំពេញកាតព្វកិច្ចនានារបស់ធនាគារ ANZ Royal នោះឡើយ។

ទំព័រ ឬ URL សម្រាប់សេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត និង ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងមណ្ឌលគាំទ្រសេវាកម្មធនាគារ ANZ Royal តាមប្រព័ន្ធអ៊ីនធឺណែត។

## ប្រទេសកម្ពុជា

ទំព័រ ឬ URL: http://www.anzroyal.com

ម៉ោងពេលប្រតិបត្តិការ: 24ម៉ោង/7ថ្ងៃ

លេខទូរស័ព្ទសម្រាប់ការហៅក្នុងស្រុក: 023 999 000 (អត្រានៃការហៅចេញអាចនឹងត្រូវគេគិតសម្រាប់ទូរស័ព្ទដៃ និង ទូរស័ព្ទសាធារណៈដែលប្រើប្រាស់កាត)។

សម្រាប់ការហៅពីក្រៅប្រទេស សូមចុចលេខ +855 23 999 000 (អត្រាការហៅពីក្រៅប្រទេសអាចនឹងត្រូវគេគិត)។